UNITED NATIONS
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# សេចក្តីថ្លែងការណ៍របស់លោកភីធើរ លយប្រែកតី
# តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
# ប្រចាំនៅកម្ពុជា នាសម័យប្រជុំលើកទី៦១ របស់គណៈកម្មការសិទ្ធិមនុស្ស របៀបវារៈទី១៩
# ក្រុងហ្សឺណែវ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៥

លោកប្រធាន
លោក លោកស្រី ជាទីគោរពរាប់អាន

យើងទាំងអស់គ្នាមានបំណងនាំមក និងទទួលព័ត៌មានណាដែលល្អ ជាជាងព័ត៌មានមិនល្អ ។ នៅក្នុងរយៈកាលជិតប្រាំឆ្នាំកន្លងមកនេះ ខ្ញុំបានដើរតួនាទីជាតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ខ្ញុំបានខិតខំប្រឹងប្រែងធ្វើរបាយការណ៍ ដោយគ្មានលំអៀងពីការពិតនៅក្នុងប្រទេសនេះ ដើម្បីជួយដល់ប្រទេសនេះ តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍អន្តរជាតិ និងកិច្ចខិតខំប្រឹងប្រែងរបស់ខ្ញុំផ្ទាល់ ដើម្បីជំនះឱ្យបាននូវឧបសគ្គទាំងឡាយដែលកើតមាន និងដើម្បីធ្វើឱ្យមានការរីកចំរើនឆ្ពោះទៅរកការគោរពសិទ្ធិមនុស្ស នីតិរដ្ឋ និងលិទ្ធិប្រជាធិបតេយ្យពហុបក្ស ។ ជួនកាល ខ្ញុំមានអារម្មណ៍ថាមានពន្លឺខ្លះហើយក្នុងដំណើរការលិទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ហើយខ្ញុំបានធ្វើសេចក្តីរាយការណ៍ទៅតាមសភាពជាក់ស្តែង ខ្ញុំមានសេចក្តីសោកស្តាយណាស់ដែលថា នៅពេលនេះ ខ្ញុំមានព័ត៌មានល្អតិចតួចដើម្បីរាយការណ៍ជូន ។

បន្ទាប់ពីជាប់គាំងផ្នែកនយោបាយអស់រយៈពេលជិតមួយឆ្នាំមក រដ្ឋាភិបាលចំរុះថ្មីមួយត្រូវបានបង្កើតឡើងកាលពីខែកក្កដាឆ្នាំមុន ។ លក្ខខណ្ឌនៃការបង្កើតឱ្យមានរដ្ឋាភិបាលចំរុះនេះ យ៉ាងហោចណាស់ ក៏មានភាពមន្ទិលសង្ស័យលើទិដ្ឋភាពផ្នែករដ្ឋធម្មនុញ្ញ និងច្បាប់ផងដែរ ហើយវាមិនបានបង្ហាញឱ្យឃើញពីឆន្ទៈរបស់អ្នកកាន់អំណាចក្នុងការគោរពនីតិរដ្ឋឡើយ ។ មានការចាត់វិធានការផ្សេងៗ ទៅលើគណៈបក្សប្រឆាំង ដោយរំលោភទៅលើគោលការណ៍ជាមូលដ្ឋានស្តីពីលិទ្ធិប្រជាធិបតេយ្យពហុបក្ស ។ ក្រៅពីនេះ ការបង្ក្រាបលើសេរីភាពក្នុងការប្រជុំដោយសន្តិវិធី "នៅទីសាធារណៈ" ក៏កើនឡើងជាលំដាប់ ។ អ្វីដែលយើងឃើញក្នុងពេលបច្ចុប្បន្ននេះ គឺការគួរឱ្យសោកស្តាយដែលវាមិនបង្ហាញឱ្យឃើញថា មានការរីកចំរើននៅលើផ្លូវមួយឆ្ពោះទៅកាន់លិទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស ផ្ទុយទៅវិញ គេសង្កេតឃើញមានការកើនឡើងនៃទម្រង់រដ្ឋាភិបាលអត្តាធិបតេយ្យ និងការប្រមូលផ្តុំអំណាចនៅក្នុងដៃរបស់នាយករដ្ឋមន្ត្រី ដែលស្ថិតនៅពីក្រោយមុខមាត់លទ្ធិប្រជាធិបតេយ្យមិនរឹងមាំ ។

ខ្ញុំបានលើកឡើងជាច្រើនសារមកហើយ អំពីបាតុភូតពីរដែលទាក់ទងគ្នា ហើយវាចាក់ឫសយ៉ាងជ្រៅនៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់កម្ពុជាបច្ចុប្បន្ន គឺបញ្ហានីទណ្ឌភាព និងអំពើពុករលួយ ។

បញ្ហានីទណ្ឌភាពគឺជាដំបៅរ៉ាំរ៉ៃដែលធ្វើឱ្យខូចមុខមាត់នៃសង្គមកម្ពុជា ។ ទោះបីជាបាតុភូតនេះ ត្រូវបានរៀបចំចងក្រងយ៉ាងត្រឹមត្រូវហើយក៏ដោយ ក៏លោកនាយករដ្ឋមន្ត្រី និងរដ្ឋាភិបាលរបស់លោក នៅតែបន្តជំនះ និងមិនអើពើ ដោយនិយាយថា បញ្ហានេះមិនកើតមាននៅក្នុងប្រទេសកម្ពុជាទេ ផ្ទុយទៅវិញ វាកើតមាននៅប្រទេស

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១០ ផ្លូវលេខ ៣០២ សង្កាត់បឹងកេងកង ១ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧

ដទៃ ដូចជាប្រទេសថៃជាដើម ។ ការពិតនោះ មិនមានយន្តការទទួលខុសត្រូវនៅក្នុងប្រទេសកម្ពុជាទេ អាស្រ័យហេតុនេះហើយ ទើបនីតិរដ្ឋនៅតែមានភាពស្រពិចស្រពិលនៅឡើយ ។

បញ្ហានីទណ្ឌភាពបង្កឱ្យមានការរីករាលដាលនៃអំពើពុករលួយ ហើយនៅតែជាឧបសគ្គសំរាប់ការបង្កើតឱ្យមាននីតិរដ្ឋ និងការធ្វើឱ្យសំរេចនូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមសំរាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ តែមិនមែនសំរាប់មនុស្សដែលមានអំណាចខាងនយោបាយ ឬសេដ្ឋកិច្ចមួយចំនួនតូចប៉ុណ្ណោះទេ ។

ភាពក្រីក្រមិនទាន់បានកាត់បន្ថយនៅឡើយ ចំពោះប្រជាពលរដ្ឋកម្ពុជាភាគច្រើន ។ ប្រជាពលរដ្ឋកម្ពុជាភាគច្រើនស្ថិតនៅក្នុងភាពក្រីក្រ ។ ទោះជាសង្គមណាក៏ដោយ កាលណាចំនួនអ្នកក្រីក្រដែលគ្មានអ្វីពឹងផ្អែកបានទាល់តែសោះកាន់តែកើនឡើង នាំឱ្យមានភាពវឹកវរនៅក្នុងសង្គម ។

គោលនយោបាយអាណានិគមបែបថ្មីនៃសម្បទានគឺជាការបរាជ័យមួយ ហើយគួរតែធ្វើការពិចារណាឡើងវិញ ។ គោលនយោបាយនេះបង្ហាញឱ្យឃើញពីការមិនគិតគូរអំពីសិទ្ធិមនុស្សនិងសុខមាលភាពនៃប្រជាពលរដ្ឋដែលពាក់ព័ន្ធ ។ ខ្ញុំបានសំដែងការស្វាគមន៍ ចំពោះសន្ទរកថារបស់លោក នាយករដ្ឋមន្ត្រី ដែលបានថ្លែងកាលពីថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៤ ដែលក្នុងសន្ទរកថានោះ លោកបានប្រកាសផ្អាក ការផ្តល់កិច្ចសន្យាសម្បទានដីគោលដៅសេដ្ឋកិច្ច រហូតដល់មានបញ្ញត្តិច្បាប់ចាំបាច់ សំរាប់អនុវត្តច្បាប់ចូលជាធរមានជាមុនសិន ។ ចំពោះបញ្ហានេះ លោកនាយករដ្ឋមន្ត្រីបានធ្វើឱ្យភ្ញាក់ផ្អើល និងសោកស្តាយជាពន់ពេក ដោយបានថ្លែងកាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៥ បានផ្លាស់ប្តូរគំនិត១៨០អង្សា ។ ព័ត៌មានទាំងអស់ស្តីពីសម្បទាន ដែលមានផលប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា គួរតែចាត់ទុកជាបញ្ហារួម ។

ទន្ទឹមនឹងនេះក៏មានព័ត៌មានល្អមួយដែរ : គឺការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ដែលគេទន្ទឹងរង់ចាំរយៈពេលដ៏យូរ នឹងត្រូវចាប់ផ្តើមនៅពេលដ៏ឆាប់ៗខាងមុខនេះហើយ ។ ប្រជាពលរដ្ឋកម្ពុជា មានបំណងដ៏ត្រឹមត្រូវចង់ដឹងពីការពិតអំពីរយៈពេលដ៏ឈឺចាប់ខ្លោចផ្សាបំផុត នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ហើយប្រជាពលរដ្ឋកម្ពុជាចង់ឃើញយុត្តិធម៌ ។ ការកាត់សេចក្តីត្រូវតែធ្វើជាគំរូមួយសំរាប់ការគោរពគោលការណ៍នៃការកាត់សេចក្តីប្រកបដោយភាពត្រឹមត្រូវនិងយុត្តិធម៌ ។ ប្រសិនបើអាចធ្វើបាន វានឹងអាចជាប្រយោជន៍វិជ្ជមានសំរាប់រយៈពេលយូរអង្វែង ក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ នៅក្នុងប្រទេសកម្ពុជា ។

របបនាសម្ព័ន្ធគ្រប់គ្រងអំណាចដែលពុករលួយ គ្មានតម្លាភាព ភាពមិនស្មើគ្នាចំពោះមុខច្បាប់ និទណ្ឌភាព ការឃុបឃិត និងការខ្វះការទទួលខុសត្រូវ គឺស្ថិតនៅក្នុងចំណោមឧបសគ្គធំៗនៅលើផ្លូវឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងសិទ្ធិមនុស្សពិតប្រាកដ សិទ្ធិមនុស្សទាំងអស់ គឺជាសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ។ រដ្ឋាភិបាលត្រូវដោះស្រាយនិងជំនះឱ្យបាននូវឧបសគ្គទាំងនេះ ហើយយើងត្រូវតែឃើញថា រដ្ឋាភិបាលពិតជាខិតខំប្រឹងប្រែងយ៉ាងពិតប្រាកដ មិនមែនជាការខិតខំប្រឹងប្រែងត្រឹមតែបបូរមាត់នោះឡើយ ។ បើពុំដូច្នោះទេ មិនអាចរំដោះឱ្យរួចផុតពីការភ័យខ្លាច និងភាពក្រីក្រ ដូចដែលបានប្រកាសនៅក្នុងបុព្វកថា នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស នឹងមិនត្រូវបានបំពេញយ៉ាងត្រឹមត្រូវតាមការសន្យាសំរាប់ប្រជាពលរដ្ឋកម្ពុជាឡើយ ។

សហគមន៍អន្តរជាតិ និងគណៈកម្មការរបស់លោក នឹងប្រឈមមុខនឹងការទទួលខុសត្រូវយ៉ាងធ្ងន់ធ្ងរ ។ ដើម្បីធ្វើឱ្យមានប្រយោជន៍ និងមានប្រសិទ្ធិភាព ដើម្បីជួយដល់ប្រជាពលរដ្ឋកម្ពុជាពីប្រវត្តិសាស្ត្រនេះ សេចក្តីសំរេចចិត្តដែលលោកត្រូវអនុម័ត គួរតែផ្អែកលើហេតុការណ៍ជាក់ស្តែង និងមិនត្រូវផ្អែកលើអ្វីដែលលោកចង់បាននោះឡើយ ។